- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ដំឡើងឋានន្តរស័ក្តិវរអគ្គានុរក្សដល់មន្ត្រីពន្ធនាគារ ចំនួន ០៣ នាក់ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ មានរាយនាមដូចខាងក្រោម៖

១- លោក **រី រ៉ែន** អត្តលេខ ០៥២៦ ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ ២ មកឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ ១

២- លោក **គ្រុយ លឹមហ៊ាង** អត្តលេខ ០២១២ ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ ២ មកឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ ១

៣- លោកស្រី **ឌឹម ធីតា** អត្តលេខ ០៣៨២ ពីឋានន្តរស័ក្តិអគ្គានុរក្ស ថ្នាក់លេខ ២ មកឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ ១ ។

មាត្រា ២.—

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣.—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃអង្គារ ២ កើត ខែ បុស្ស ឆ្នាំ រកា ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ គ.ស ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..១៤៥៥..អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំង និងផ្តល់ឋានៈដល់មន្ត្រីចំនួន ០៣រូប ជាទីប្រឹក្សាក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកស្រី **អ៊ិត យុត** មានឋានៈស្មើ អគ្គនាយករង

២- លោក **ពុធ សារុន** មានឋានៈស្មើ អគ្គនាយករង

៣- លោក **ហុក រិន** មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៤ កើត ខែ បុស្ស ឆ្នាំរកា ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ១ គ.ស២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ...៥៧៦......... ប្រក.កសក

ប្រកាស
ស្តីពី
ការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មផ្លាក់ធាតុអាស័យជីវសាស្ត្រ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា២៧ និងមាត្រា៣៤ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដី

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh Cambodia Phone: (023) 726 128 / 726 129, Fax : (855) 23 - 217 320

កសិកម្ម ឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្ម រាជធានី ខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឲ្យស្ថិតនៅក្រោមមន្ទីរកសិកម្ម រាជធានី ខេត្ត
- បានឃើញសេចក្តីសម្រេចលេខ២៣៤ សសរ.កសក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការចាត់តាំងមន្ត្រីអធិការកិច្ចថ្នាក់កសិកម្ម និងជីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

ប្រការ ១.-

អនុញ្ញាតឲ្យនាយកដ្ឋាននីតិកម្មកសិកម្ម ប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ "Biological Control Agents" ដែលជាធាតុចូលក្នុងផលិតកម្មកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា "ដូចមានភ្ជាប់ឧបសម្ព័ន្ធនៃប្រកាសនេះ" ស្រាប់ ដូចខាងក្រោម៖

- ទម្រង់ស្នើសុំចុះបញ្ជីភ្នាក់ងារជីវសាស្ត្រ
- វិញ្ញាបនបត្របញ្ជាក់បញ្ជិកាភ្នាក់ងារជីវសាស្ត្រ
- លិខិតអនុញ្ញាតនាំចូលនាំចេញភ្នាក់ងារជីវសាស្ត្រ
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិភ្នាក់ងារជីវសាស្ត្រ
- លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីភ្នាក់ងារជីវសាស្ត្រ
- លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយភ្នាក់ងារជីវសាស្ត្រ
- លិខិតអនុញ្ញាតអាជីវកម្មលក់ដុំលក់រាយភ្នាក់ងារជីវសាស្ត្រ (i)
- លិខិតអនុញ្ញាតអាជីវកម្មលក់ដុំលក់រាយភ្នាក់ងារជីវសាស្ត្រ (ii)។

ប្រការ ២.-

នាយកដ្ឋាននីតិកម្មកសិកម្ម មានភារកិច្ច ដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ និងកសាងសមត្ថភាពមន្ត្រីនៃនាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ត្រីនៃការិយាល័យនីតិកម្មកសិកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត លើផ្នែកភ្នាក់ងារជីវសាស្ត្រ
- ស្វែងរកដៃគូអភិវឌ្ឍន៍សម្រាប់ជួយកសាងសមត្ថភាពមន្ត្រីនៃនាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ត្រីនៃការិយាល័យនីតិកម្មកសិកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត
- រៀបចំគោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្ម និងការប្រើប្រាស់ភ្នាក់ងារជីវសាស្ត្រ ប្រកបដោយប្រសិទ្ធភាព
- អប់រំ ផ្សព្វផ្សាយអំពីស្តង់ដារបច្ចេកទេស គោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងភ្នាក់ងារជីវសាស្ត្រ ដល់ពាណិជ្ជករ ប្រតិបត្តិករ អាជីវករ និងអ្នកប្រើប្រាស់ភ្នាក់ងារជីវសាស្ត្រ
- ទទួលបន្ទុកសម្របសម្រួលរៀបចំសំណុំឯកសារសម្រាប់ចុះបញ្ជីភ្នាក់ងារជីវសាស្ត្រ និងលិខិតអនុញ្ញាតផ្សេងៗ ទៀតជូនអ្នកស្នើសុំ
- ទទួលភារកិច្ចផ្សេងៗ ទៀតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រការ ៣.-

មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម ដែលបានកំណត់ក្នុងសេចក្តីសម្រេចលេខ ២៣៤ សសរ.កសក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ មានសមត្ថកិច្ចតាមដាន និងត្រួតពិនិត្យបទល្មើសលើគ្រប់សកម្មភាពពាក់ព័ន្ធនឹងភ្នាក់ងារជីវសាស្ត្រគ្រប់ប្រភេទ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម។

ប្រការ ៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៥.-

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៧

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

កន្លែងទទួល ៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ៥
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ

នៃប្រកាសលេខ [illegible] ប្រក.កសក ចុះថ្ងៃទី១១ ខែ កញ្ញា ឆ្នាំ២០១៧
ស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ

ល.រ	ឈ្មោះគំរូឯកសារ	ផ្សេងៗ
០១	ទម្រង់ស្នើសុំចុះបញ្ជីភ្នាក់ងារជីវសាស្ត្រ៖ -ទម្រង់ស្នើសុំចុះបញ្ជីភ្នាក់ងារអតិសុខុមប្រាណកម្ចាត់សមាសភាពចង្រៃ -ទម្រង់ស្នើសុំចុះបញ្ជីភ្នាក់ងារផលិតផលធម្មជាតិការពារដំណាំ -ទម្រង់ស្នើសុំចុះបញ្ជីភ្នាក់ងារអន្ទាក់ស្នេហ៍កម្ចាត់សត្វល្អិត	ចំនួន០៣ច្បាប់
០២	វិញ្ញាបនបត្របញ្ជាក់បញ្ជិកាភ្នាក់ងារជីវសាស្ត្រ	ចំនួន០១ច្បាប់
០៣	វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិភ្នាក់ងារជីវសាស្ត្រ	ចំនួន០១ច្បាប់
០៤	លិខិតអនុញ្ញាតនាំចូលនាំចេញភ្នាក់ងារជីវសាស្ត្រ	ចំនួន០១ច្បាប់
០៥	លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីភ្នាក់ងារជីវសាស្ត្រ	ចំនួន០១ច្បាប់
០៦	លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយភ្នាក់ងារជីវសាស្ត្រ	ចំនួន០១ច្បាប់
០៧	លិខិតអនុញ្ញាតអាជីវកម្មលក់ដុំលក់រាយភ្នាក់ងារជីវសាស្ត្រ (ក)	ចំនួន០១ច្បាប់
០៨	លិខិតអនុញ្ញាតអាជីវកម្មលក់ដុំលក់រាយភ្នាក់ងារជីវសាស្ត្រ (ខ)	ចំនួន០១ច្បាប់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទម្រង់ស្នើសុំចុះបញ្ជីភ្នាក់ងារជីវសាស្ត្រ

"APPLICATION FORM FOR BIOLOGICAL CONTROL AGENTS' REGISTRATION"

១-ព័ត៌មានអ្នកស្នើសុំ (Applicant's details)

-ឈ្មោះអ្នកស្នើសុំ (Applicant name) ....ភេទ (Gender) ....

-ថ្ងៃ ខែ ឆ្នាំកំណើត (Date of Birth) ....

-ទីកន្លែងកំណើត (Place of Birth) ....

-សញ្ជាតិ (Nationality) ....

-អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនលេខ (ID/Passport N^0) ....

-កាលបរិច្ឆេទផុតសុពលភាពនៃអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (Expired Date of ID/Passport)

....

-តួនាទីក្នុងក្រុមហ៊ុន (Position in Company)..

-អាសយដ្ឋានក្រុមហ៊ុននៅកម្ពុជា (Company Address in Cambodia) ....

....។

-ទូរស័ព្ទ/ទូរសារ (Phone/Fax) ....

-គេហទំព័រ (Home page) ....

-ចុះបញ្ជីពាណិជ្ជកម្ម (Trade Registration) ....

-ទីតាំងគ្រឹះស្ថានផលិត (Location of Products) ....

....។

២-ប្រភេទនៃភ្នាក់ងារជីវសាស្ត្រ (Type of Biological Control Agents)

☐-អតិសុខុមប្រាណកម្ចាត់សមាសភាពចង្រៃ (Microbial)

☐-ផលិតផលធម្មជាតិ (Natural Product)

☐-អន្ទាក់ស្នេហ៍កម្ចាត់សត្វល្អិត (Semiochemical) ដែលភាគច្រើនជាផេរ៉ូម៉ូន (Pheromones) ឬកៃរ៉ូម៉ូន (Kairomones)

៣-គោលបំណងនៃការស្នើសុំ (Purpose of application)

☐-ជំនួញ (Business or full registration)

☐-សាកល្បង (Testing by using EUP= Experimental Use Permit)

☐-ផ្សេងៗ (others)

៤-ធាតុសកម្ម (Active ingredients) ....

៥-ឈ្មោះពាណិជ្ជកម្ម (Trade name) ....

ឧបសម្ព័ន្ធនៃប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ

៦-អ្នកផ្គត់ផ្គង់/ប្រទេសប្រភពដើមផលិតសម្រាប់នាំចេញ និងអាសយដ្ឋាន (Distributor / Country origin & Address) ....។
៧-វិញ្ញាបនបត្រពីក្រុមហ៊ុនមេ (Certificate from mother company) ....។
៨-ប្រភេទប្រើប្រាស់ (Use type (e.g. insecticide, acaricide, rodenticide, etc.) ....។
៩-ប្រភេទបញ្ជិកា (Registration type/state) ☐ ផលិតផលសម្រេច (Formulated product), ☐ ជាតុសកម្មសម្រាប់កែច្នៃបន្ថែម (technical grade)

តម្រូវការព័ត៌មានសម្រាប់ចុះបញ្ជីភ្នាក់ងារអតិសុខុមប្រាណការពារដំណាំ
កម្ចាត់សមាសភាពចង្រៃដែលបានដាក់បញ្ចូលសរីរាង្គមានជីវិតជាភ្នាក់ងារសកម្ម
(Data Requirements for Microbials' Registration)
(**ពាក្យគន្លឹះ** R= តម្រូវការចាំបាច់ C= លក្ខខណ្ឌ NA= មិនអាចអនុវត្តបាន និង NR= មិនតម្រូវការ)

តម្រូវការថ្នាក់ទី១

ល.រ	ឯកសារតម្រូវ	ធាតុសកម្ម (A.I)	រូបមន្តនៃការផលិត
	(ក)- លក្ខណៈជីវសាស្ត្រ និងគីមី		
១	ឈ្មោះជាប្រព័ន្ធ ឬឈ្មោះវិទ្យាសាស្ត្រ	R	R
២	ពូជ/ឬជាតុសកម្ម	R	R
៣	ឈ្មោះទូទៅ	R	R
៤	ប្រភពដើម និងលក្ខណៈសកម្ម ឬមុខងារនៃសារជាតុសកម្ម	R	R
៥	យថាប្រភេទ (លក្ខណៈបច្ចេកទេស) នៃផលិតផល	R	R
៦	សមាសភាពនៃផលិតផល	R	R
៧	ដំណើរការផលិត	R	R
៨	នីតិវិធីនៃការធ្វើពិសោធន៍ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់អត្តសញ្ញាណ	R	R
៩	ភាពមិនសុទ្ធ និងការចម្លងជំងឺ	R	R
១០	អំណះអំណាងពីសុពលភាពនៃការផ្គត់ផ្គង់ចែកចាយ	C	R
១១	សំណាកសម្រាប់ការផ្ទៀងផ្ទាត់	C	R
	(ខ)- ការឆ្លងជំងឺ ឬការបំពុលដល់សរីរាង្គមិនមែនគោលដៅ		

១២	ការឆ្លងជំងឺ និងលទ្ធភាពបង្កជំងឺ	R	
១៣	ការពិសោធន៍លើកម្រិតបំពុល (ក្នុងករណីមានការសង្ស័យ)	C	C
	(គ)- ជីវប្រសិទ្ធភាព		
១៤	ការសិក្សានៅទីវាល	NA	R
១៥	ការសិក្សានៅមន្ទីរពិសោធន៍ (Optional)	C	C
	(ឃ)- ដំណើរការកែច្នៃ វេចខ្ចប់ និងការបិទស្លាកសញ្ញាព័ត៌មាន		
១៦	ដំណើរការផលិត	NA	R
១៧	ព័ត៌មានស្តីពីការប្រើប្រាស់ និងការធ្វើសន្និធិ	C	R
១៨	ស្លាកសញ្ញាព័ត៌មាន និងខិតប័ណ្ណផ្សព្វផ្សាយ	NA	R

តម្រូវការថ្នាក់ទី ២

	(ង)- ទិន្នន័យកាកសំណល់ -តម្រូវការព័ត៌មានបន្ថែម ប្រសិនបើកាកសំណល់នៃភ្នាក់ងារសកម្ម អាចនឹងរំពឹងថានៅក្នុងចំណីអាហារ ឬគ្រឿងបរិភោគ -សារធាតុដែលត្រូវប្រើប្រាស់សម្រាប់ការផលិត មិនត្រូវបន្សល់ទុកកាកសំណល់ក្នុងចំណីអាហារ ឬគ្រឿងបរិភោគឡើយ។	C	C
	កំណត់សម្គាល់៖ -ផ្អែកតាមបទពិសោធន៍ និងកស្តុតាងដែលមានមកដល់បច្ចុប្បន្ន គេសន្និដ្ឋានថា ធម្មជាតិនៃភ្នាក់ងារ-អតិសុខុមប្រាណកម្ចាត់សមាសជាតុចង្រៃមិនផលិតកាកសំណល់គីមីក្នុងចំណីអាហារ នោះទេ -មេតាបូលីត (Metabolites) របស់ភ្នាក់ងារអតិសុខុម-ប្រាណ ជាទូទៅ វារលាយបាត់យ៉ាងរហ័ស -វត្តមានរបស់មីក្រូសរីរាង្គត្រូវបានគេបញ្ចូលទៅក្នុងប្រព័ន្ធកសិអេកូឡូស៊ី ទោះបីជាមីក្រូសរីរាង្គទាំងនោះមិនអាចរស់នៅបានយូរក្នុងចំណីអាហារក៏ដោយ គឺជាបញ្ហាលក្ខខណ្ឌបរិស្ថាន និងជម្រករបស់វា។ ក្នុងករណីជាច្រើន មីក្រូ-សរីរាង្គដែលបានប្រើជាភ្នាក់ងារជីវសាស្ត្រ អាចនឹងមានវត្តមានរួចមកហើយក្នុងបរិស្ថាន ហើយការប្រើប្រាស់អាចនឹងនាំទៅរកការផ្លាស់ប្តូរបណ្តោះអាសន្ននៅក្នុងសមាសជាតុនៃបណ្តុំអតិសុខុមប្រាណ (Microflora របស់ដី)។		

	(ច)- ទិន្នន័យស្តីពីការប្រឈមនឹងសុខភាពមនុស្ស/ និងផលប៉ះពាល់បរិស្ថាន	C	C
	កំណត់សម្គាល់៖ -ផលប៉ះពាល់ដល់សុខភាពមនុស្សពីការធ្វើពិសោធន៍នឹងសត្វ ប្រសិនបើភ្នាក់ងារអតិសុខុមប្រាណកម្ចាត់សមាសភាពចង្រៃ ស្ថិតក្នុងប្រភេទណាមួយនៃការព្រួយបារម្ភ។ ការកំណត់អត្តសញ្ញាណថាតើមានផលប៉ះពាល់ដែរឬទេ (ឧទាហរណ៍ មិនរាប់បញ្ចូលលទ្ធផលពីការសម្របសម្រួលទេ)។ ជាតុបង្កជំងឺមនុស្ស មានន័យថា ការបដិសេធរបស់ភ្នាក់ងារសេកម្ម មិនរាប់បញ្ចូលបុគ្គលខ្វះភាពស៊ាំទេ -រហូតមកដល់ពេលនេះ មិនទាន់មានមីក្រូសរីរាង្គណាមួយដែលជាភ្នាក់ងារជីវសាស្ត្រ នៅទូទាំងពិភពលោកបង្ហាញផលប៉ះពាល់ CMR (Carcinogens, Mutagenicity Reproductive toxicity) ដែលជាសារជាតុបង្កជាជំងឺមហារីក ឬបំពុលដល់ការបន្តពូជឡើយ។ លទ្ធផលដែលបានមកពីកម្មវិធីតាមដាន និងសម្រង់មតិសុខភាព និងសុវត្ថិភាពកម្មករនៅតំបន់ផលិតត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃហានិភ័យសុខភាពមនុស្សទូទៅ -ជាទូទៅ គេមិនចាំបាច់មានការស៊ើបអង្កេតទៅលើការបំបែកជាតុ និងចលនានៅក្នុង និងរវាងថតមួយទៅថតមួយទៀតនោះទេ បើសិនគេបានធ្វើតេស្តអំពីហានិភ័យនៃការរីករាលដាលជាមុននៅក្នុងទ្រនំ(ជួល)ផ្សេងៗ និងការឆ្លងរោគពីគ្នាជាដើម។ល។ តាមលក្ខណៈបច្ចេកទេស ការតាមដានមីក្រូសរីរាង្គក្នុងទីបើកចំហរ គឺអាចសម្រេចបានដោយប្រើប្រាស់វិធីសាស្ត្រធ្វើរោគវិនិច្ឆ័យហ្សែន (ឧទាហរណ៍ PCR (Standard for Polymerase Chain Reaction) ដោយប្រើសញ្ញាសម្គាល់ដាក់លាក់សម្រាប់ភ្នាក់ងារជីវសាស្ត្រ និងគោលដៅរបស់វា។		
	(ឆ)- តម្រូវការទិន្នន័យបន្ថែម	C	C

១០-សេចក្តីអះអាងរបស់អ្នកស្នើសុំ (Certification/ Clarification of Applicant)

ខ្ញុំសូមអះអាងថា ពល់ព័ត៌មាន និងឯកសារជូនភ្ជាប់ទាំងអស់សម្រាប់ស្នើសុំចុះបញ្ជី និងការកំណត់អត្តសញ្ញាណនៃភ្នាក់ងារជីវសាស្ត្រ ខាងលើ គឺពិតជាត្រឹមត្រូវ ប្រាកដមែន។

ប្រសិនបើលទ្ធផលវាយតម្លៃតម្រូវការព័ត៌មានថ្នាក់ទី១ (Tier 1) នៅមិនទាន់គ្រប់គ្រាន់ សូមពិនិត្យព័ត៌មានបន្ថែមក្នុងតម្រូវការព័ត៌មានថ្នាក់ទី២ (Tier 2) ទៀត។

ដើម្បីជាសក្ខីភាពនាពេលនេះ ខ្ញុំសូមចុះហត្ថលេខា ឬផ្តិតមេដៃជាកស្តុតាង ដូចខាងក្រោម៖

រាជធានីភ្នំពេញ, ថ្ងៃទី (Day) .... ខែ (Month) .... ឆ្នាំ (Year) ២០ ...

ហត្ថលេខា និងត្រា (Signature/ Stamp of Firm)

១១-សម្រាប់នាយកដ្ឋាននីតិកម្មកសិកម្ម (Department of Agricultural Legislation use only)

-សំណុំឯកសារស្នើសុំលេខ (Document's application N⁰) ....

-កាលបរិច្ឆេទទទួល (Received Date) ....

-វិក្កយបត្របង់ប្រាក់សេវាកម្មលេខ (Service Invoice N°) ....

-វិក្កយបត្របង់ប្រាក់សេវាកម្មពិសោធន៍លេខ (Service Invoice for Analyze of BCA N°) ....

-សំណាកសម្រាប់ធ្វើពិសោធន៍ (Sample for testing) ....

-កាលបរិច្ឆេទផុតសុពលភាព (Out of expiry's date) ....

-កំណត់សម្គាល់ (Note) ....

-ឈ្មោះមន្ត្រីទទួលឯកសារ និងសំណាក (Receiver name) ....

....។

ᧁ🕮ᧂ

ទំព័រ ៥/៥

ឧបសម្ព័ន្ធនៃប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទម្រង់ស្នើសុំចុះបញ្ជីភ្នាក់ងារជីវសាស្ត្រ

"APPLICATION FORM FOR BIOLOGICAL CONTROL AGENTS' REGISTRATION"

១-ព័ត៌មានអ្នកស្នើសុំ (Applicant's details)

-ឈ្មោះអ្នកស្នើសុំ (Applicant name) ....ភេទ (Gender) ....

-ថ្ងៃ ខែ ឆ្នាំកំណើត (Date of Birth) ....

-ទីកន្លែងកំណើត (Place of Birth) ....

-សញ្ជាតិ (Nationality) ....

-អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនលេខ (ID/Passport N^0) ....

-កាលបរិច្ឆេទផុតសុពលភាពនៃអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (Expired Date of ID/Passport)

....

-តួនាទីក្នុងក្រុមហ៊ុន (Position in Company)..

-អាសយដ្ឋានក្រុមហ៊ុននៅកម្ពុជា (Company Address in Cambodia) ....

....។

-ទូរស័ព្ទ/ទូរសារ (Phone/Fax) ....

-គេហទំព័រ (Home page) ....

-ចុះបញ្ជីពាណិជ្ជកម្ម (Trade Registration) ....

-ទីតាំងគ្រឹះស្ថានផលិត (Location of Products) ....

....។

២-ប្រភេទនៃភ្នាក់ងារជីវសាស្ត្រ (Type of Biological Control Agents)

☐-អតិសុខុមប្រាណកម្ចាត់សមាសភាពចង្រៃ (Microbial)

☐-ផលិតផលធម្មជាតិ (Natural Product)

☐-អន្ទាក់ស្នេហ៍កម្ចាត់សត្វល្អិត (Semiochemical) ដែលភាគច្រើនជាផេរ៉ូម៉ូន (Pheromones) ឬកៃរ៉ូម៉ូន (Kairomones)

៣-គោលបំណងនៃការស្នើសុំ (Purpose of application)

☐-ជំនួញ (Business or full registration)

☐-សាកល្បង (Testing by using EUP= Experimental Use Permit)

☐-ផ្សេងៗ (others)

៤-ធាតុសកម្ម (Active ingredients) ....

៥-ឈ្មោះពាណិជ្ជកម្ម (Trade name) ....

៦-អ្នកផ្គត់ផ្គង់/ប្រទេសប្រភពដើមផលិតសម្រាប់នាំចេញ និងអាសយដ្ឋាន (Distributor / Country origin & Address) .... ។
៧-វិញ្ញាបនបត្រពីក្រុមហ៊ុនមេ (Certificate from mother company) .... ។
៨-ប្រភេទប្រើប្រាស់ (Use type (e.g. insecticide, acaricide, rodenticide, etc.) .... ។
៩-ប្រភេទបញ្ជិកា (Registration type/state) ☐ ផលិតផលសម្រេច (Formulated product), ☐ ជាតុសកម្មសម្រាប់កែច្នៃបន្ថែម (technical grade)

តម្រូវការព័ត៌មានសម្រាប់ចុះបញ្ជីផ្លាក់ខារផលិតផលធម្មជាតិ ជាសមាសធាតុ ឬគីមីជីវសាស្ត្រចម្រាញ់ពីសរីរាង្គមានជីវិត និងរុក្ខជាតិ ប្រើប្រាស់ដើម្បីការពារដំណាំ (**ឧទាហរណ៍** Botanicals)

(Data Requirements for Natural Products' Registration)

(**ពាក្យកាត់៖** R= តម្រូវការចាំបាច់ C= លក្ខខណ្ឌ NA= មិនអាចអនុវត្តបាន និង NR= មិនតម្រូវការ)

តម្រូវការថ្នាក់ទី ១

ល.រ	ឯកសារតម្រូវ	ធាតុសកម្ម (A.I.)	រូបមន្ត នៃការផលិត
	(ក)- លក្ខណៈជីវសាស្ត្រ និងគីមី		
១	ឈ្មោះជាប្រព័ន្ធ (ប្រភេទ ឬអំបូររបស់ដំណាំ)		R
២	ឈ្មោះទូទៅ		R
៣	ប្រភព និងដើមកំណើត		R
៤	យថាប្រភេទ (លក្ខណៈបច្ចេកទេសនៃផលិតផល)		R
៥	ការកំណត់លក្ខណៈផលិតផល (វិធីសាស្ត្រនៃការធ្វើវិភាគ Analytical approach optional)៖ -ជាតុសកម្ម -រង្វាស់ជីវសាស្ត្រ (Biomarker) ភ្ជាប់ ឬមិនភ្ជាប់ទៅនឹងសកម្មភាព -ជាតុផ្សំសំខាន់ (Gross constituents)	C	R
៦	ដំណើរការផលិត (ការចម្រាញ់ ការបង្កើតរូបមន្តអាចក្លាយជាផ្នែកមួយនៃអត្តសញ្ញាណផលិតផល)		R
៧	នីតិវិធីនៃការធ្វើពិសោធន៍ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់អត្តសញ្ញាណ		R

៨	**ភាពមិនសុទ្ធ៖** -ជាតិពុលមេតាបូលីតសកម្ម (ប្រសិនមានការសង្ស័យ) -មេតាបូលីតអសកម្ម -ភ្នាក់ងារអេតិសុខុមប្រាណកម្ចាត់សមាសធាតុចង្រៃ និងភាពមិនសុទ្ធ (វិធីសាស្ត្រនៃការដេកចេញ)។		R
៩	អំណះអំណាងពីសុពលភាពនៃការផ្គត់ផ្គង់ចែកចាយ		R
១០	សំណាកសម្រាប់ការផ្ទៀងផ្ទាត់		R
	(ខ)- ការវាយតម្លៃជាតិពុល		
១១	**ការពិនិត្យហានិភ័យអប្បបរមា៖** ផលិតផលចម្រាញ់ពីធម្មជាតិ (ដូចជា ស្តៅ ជាដើម) បានទទួលស្គាល់ជាអន្តរជាតិ ដូចជា៖ -ថ្នាំសម្លាប់សត្វល្អិតមានហានិភ័យតិចបំផុត -ជាផ្នែកនៃឱសថសាស្ត្រ -ប្រវត្តិនៃការប្រើប្រាស់មានសុវត្ថិភាព។	C	R
១២	ការធ្វើពិសោធន៍រកជាតិពុល (conditional)		C ត្រូវការធ្វើពិសោធន៍ ប្រសិនបើមានការសង្ស័យ
១៣	ការធ្វើពិសោធន៍សុវត្ថិភាពបរិស្ថាន (conditional)		C ត្រូវការធ្វើពិសោធន៍ ប្រសិនបើមានការសង្ស័យ
	(គ)- ជីវប្រសិទ្ធភាព		
១៤	**ការពិសោធន៍នៅទីវាល៖** ផ្អែកលើពិធីសារបច្ចេកទេសសាកល្បងជីវប្រសិទ្ធភាព សម្រាប់ថ្នាំសម្លាប់សត្វល្អិតធម្មជាតិ (សូមមើល ឧបសម្ព័ន្ធទីIII ក្នុងសៀវភៅគោលការណ៍ណែនាំបទដ្ឋានគតិយុត្តស្តីពីការប្រើប្រាស់ និងការធ្វើពាណិជ្ជកម្មភ្នាក់ងារជីវសាស្ត្រ) របស់អាស៊ាន។ **កំណត់សម្គាល់៖** -មិនចាំបាច់តម្រូវឲ្យមានការធ្វើពិសោធន៍បន្ថែមទៀតទេ ប្រសិនបើមានទិន្នន័យស៊ីជម្រៅពីការពិសោធន៍លើផ្នែកជីវប្រសិទ្ធភាព -ជីវប្រសិទ្ធភាពរបស់ថ្នាំពុលធម្មជាតិ មានលក្ខណៈទាបជាងថ្នាំពុលគីមី។ ដូចនេះ នីតិវិធីនៃការធ្វើពិសោធន៍		R

	ក៏ខុសគ្នាពីការធ្វើពិសោធន៍ថ្នាំពុលគីមីដែរ (មិនត្រូវប្រៀបធៀបលទ្ធផលជាមួយថ្នាំពុលគីមីបានឡើយ)។		
	(ឃ)- ការវេចខ្ចប់ និងការបិទស្លាកសញ្ញាព័ត៌មាន		
១៥	ដំណើរការវេចខ្ចប់ និងព័ត៌មាននៃការធ្វើសន្និធិ		R
១៦	ការដាក់ស្លាកសញ្ញាព័ត៌មាន និងខិតប័ណ្ណផ្សព្វផ្សាយ		R

តម្រូវការថ្នាក់ទី ២

	(ង)- ទិន្នន័យកាកសំណល់ -ថ្នាំសម្លាប់សត្វល្អិតចម្រាញ់ពីរុក្ខជាតិ ជាទូទៅមិនបង្កើតកាកសំណល់នៅក្នុងម្ហូបអាហារនោះទេ ពីព្រោះវាងាយនឹងរលាយឆាប់រហ័សទៅក្នុងបរិស្ថាន -សារធាតុត្រូវបានប្រើប្រាស់សម្រាប់រូបមន្តផលិត មិនអាចផលិតកាកសំណល់នៅក្នុងម្ហូបអាហារ បានឡើយ។ ចំណុចនេះ តម្រូវឲ្យមានឯកសារយោង។	C	C
	កំណត់សម្គាល់៖ -ផ្អែកតាមបទពិសោធន៍ និងភស្តុតាងដល់សព្វថ្ងៃនេះ អាចសន្មតថា ថ្នាំសម្លាប់សត្វល្អិតរុក្ខជាតិ ជាទូទៅមិនបង្កើតកាកសំណល់គីមីពុលក្នុងម្ហូបអាហារទេ ពីព្រោះវារលាយឆាប់រហ័សទៅក្នុងបរិស្ថាន -ជាតុចម្រាញ់រុក្ខជាតិ មិនអាចបិទស្លាកវិទ្យុសកម្មសម្រាប់ការរកព័ត៌មានដើមបានឡើយ -មានករណីជាច្រើនដែលភ្នាក់ងារអតិសុខុមប្រាណទាំងឡាយ បានផលិតដូចគ្នានឹងភ្នាក់ងារជីវសាស្ត្រនៅក្នុងបរិស្ថាន ដែលអាចនាំឲ្យមានការផ្លាស់ប្តូរក្នុងដី។ ដូចនេះ ត្រូវពិនិត្យរកតែកាកសំណល់ ប្រសិនជាមានការសង្ស័យ ដោយសារតែលក្ខណៈធម្មជាតិនៃជាតុចម្រាញ់រុក្ខជាតិ ហើយកម្រិតកំណត់មួយចំនួនត្រូវបានស្នើឡើង (ឧទាហរណ៍ច្បាប់សហគមន៍អឺរ៉ុប) ហើយអាចពិចារណាផ្អែកតាមករណី។		
	(ច)- ទិន្នន័យស្តីពីការប្រឈមនឹងសុខភាពមនុស្ស/ផលប៉ះពាល់បរិស្ថាន និងប្រសិទ្ធភាព បើសិនលទ្ធផលពីថ្នាក់ទី១ តម្រូវឱ្យមានការសិក្សាវាយតម្លៃបន្ថែមនៅថ្នាក់ទី២។	C	C
	(ឆ)- តម្រូវការទិន្នន័យបន្ថែម	C	C

១០-សេចក្ដីអះអាងរបស់អ្នកស្នើសុំ (Certification/ Clarification of Applicant)

ខ្ញុំសូមអះអាងថា រាល់ព័ត៌មាន និងឯកសារជូនភ្ជាប់ទាំងអស់សម្រាប់ស្នើសុំចុះបញ្ជី និងការកំណត់អត្តសញ្ញាណភ្នាក់ងារជីវសាស្ត្រ ខាងលើ គឺពិតជាត្រឹមត្រូវ ប្រាកដមែន។

ប្រសិនបើលទ្ធផលវាយតម្លៃតម្រូវការព័ត៌មានថ្នាក់ទី១ (Tier 1) នៅមិនទាន់គ្រប់គ្រាន់ សូមពិនិត្យព័ត៌មានបន្ថែមក្នុងតម្រូវការព័ត៌មានថ្នាក់ទី២ (Tier 2) ទៀត។

ដើម្បីជាសក្ខីភាពនាពេលនេះ ខ្ញុំសូមចុះហត្ថលេខា ឬផ្ដិតមេដៃជាកស្តុតាង ដូចខាងក្រោម៖

រាជធានីភ្នំពេញ, ថ្ងៃទី (Day) .... ខែ (Month) .... ឆ្នាំ (Year) ២០ ...

ហត្ថលេខា និងត្រា (Signature/ Stamp of Firm)

១១-សម្រាប់នាយកដ្ឋាននីតិកម្មកសិកម្ម (Department of Agricultural Legislation use only)

-សំណុំឯកសារស្នើសុំលេខ (Document's application N^0) ....

-កាលបរិច្ឆេទទទួល (Received Date) ....

-វិក្កយបត្របង់ប្រាក់សេវាកម្មលេខ (Service Invoice N^o) ....

-វិក្កយបត្របង់ប្រាក់សេវាកម្មពិសោធន៍លេខ (Service Invoice for Analyze of BCA N^o) ....

-សំណាកសម្រាប់ធ្វើពិសោធន៍ (Sample for testing) ....

-កាលបរិច្ឆេទផុតសុពលភាព (Out of expiry's date) ....

-កំណត់សម្គាល់ (Note) ....

-ឈ្មោះមន្ត្រីទទួលឯកសារ និងសំណាក (Receiver name) ....

....។

៚ ៚

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទម្រង់ស្នើសុំចុះបញ្ជីភ្នាក់ងារជីវសាស្ត្រ
"APPLICATION FORM FOR BIOLOGICAL CONTROL AGENTS' REGISTRATION"

១-ព័ត៌មានអ្នកស្នើសុំ (Applicant's details)

-ឈ្មោះអ្នកស្នើសុំ (Applicant name) ....ភេទ (Gender) ....

-ថ្ងៃ ខែ ឆ្នាំកំណើត (Date of Birth) ....

-ទីកន្លែងកំណើត (Place of Birth) ....

-សញ្ជាតិ (Nationality) ....

-អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនលេខ (ID/Passport N^0) ....

-កាលបរិច្ឆេទផុតសុពលភាពនៃអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (Expired Date of ID/Passport)

....

-តួនាទីក្នុងក្រុមហ៊ុន (Position in Company)...

-អាសយដ្ឋានក្រុមហ៊ុននៅកម្ពុជា (Company Address in Cambodia) ....

....។

-ទូរស័ព្ទ/ទូរសារ (Phone/Fax) ....

-គេហទំព័រ (Home page) ....

-ចុះបញ្ជីពាណិជ្ជកម្ម (Trade Registration) ....

-ទីតាំងគ្រឹះស្ថានផលិត (Location of Products) ....

....។

២-ប្រភេទនៃភ្នាក់ងារជីវសាស្ត្រ (Type of Biological Control Agents)

☐-អតិសុខុមប្រាណកម្ចាត់សមាសភាពចង្រៃ (Microbial)

☐-ផលិតផលធម្មជាតិ (Natural Product)

☐-អន្ទាក់ស្នេហ៍កម្ចាត់សត្វល្អិត (Semiochemical) ដែលភាគច្រើនជាផេរ៉ូម៉ូន (Pheromones) ឬគៃរ៉ូម៉ូន (Kairomones)

៣-គោលបំណងនៃការស្នើសុំ (Purpose of application)

☐-ជំនួញ (Business or full registration)

☐-សាកល្បង (Testing by using EUP= Experimental Use Permit)

☐-ផ្សេងៗ (others)

៤-ធាតុសកម្ម (Active ingredients) ....

៥-ឈ្មោះពាណិជ្ជកម្ម (Trade name) ....

ឧបសម្ព័ន្ធនៃប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ

៦-អ្នកផ្គត់ផ្គង់/ប្រទេសប្រភពដើមផលិតសម្រាប់នាំចេញ និងអាសយដ្ឋាន (Distributor / Country origin & Address) .... ។
៧-វិញ្ញាបនបត្រពីក្រុមហ៊ុនមេ (Certificate from mother company) .... ។
៨-ប្រភេទប្រើប្រាស់ (Use type (e.g. insecticide, acaricide, rodenticide, etc.) .... ។
៩-ប្រភេទបញ្ជិកា (Registration type/state) ☐ ផលិតផលសម្រេច (Formulated product), ☐ ជាតុសកម្មសម្រាប់កែច្នៃបន្ថែម (technical grade)

តម្រូវការព័ត៌មានសម្រាប់ចុះបញ្ជីភ្នាក់ងារអន្ទាក់ស្នេហ៍កម្ចាត់សត្វល្អិត ជាម៉ូលេគុល ឬល្បាយនៃគីមីជីវៈដែលផ្ទុកសារជាក់លាក់ ប្រើប្រាស់ដើម្បីទាក់សត្វល្អិត តាមដានវត្តមានសត្វល្អិត និងបណ្ដេញសត្វល្អិតពីដំណាំ និងអាចធ្វើជាថ្នាំបណ្ដេញ សត្វមូស បានផងដែរ ប៉ុន្តែពួកវាមិនមានយន្តការបំពុលទេ

(Data Requirements for Semiochemicals' Registration

(**ពាក្យគន្លឹះ** R= តម្រូវការចាំបាច់ C= លក្ខខណ្ឌ NA=មិនអាចអនុវត្តបាន និង NR=មិនតម្រូវការ)

តម្រូវការថ្នាក់ទី ១

ល.រ	ឯកសារតម្រូវ	ធាតុសកម្ម (A.I)	រូបមន្ត នៃការផលិត
	(ក)- លក្ខណៈជីវសាស្ត្រ និងគីមី		
១	ការកំណត់លក្ខណៈគីមី	R	R
២	ការកំណត់លក្ខណៈរូប	R	R
	(ខ)- ការបំពុល		
៣	ទិន្នន័យនៃការបំពុល៖ ក.ការកាត់បន្ថយហានិភ័យ -ប្រសិនបើមានការបំពុលតិច និងមិនមានផលប៉ះពាល់ដល់សរីរាង្គមិនមែនគោលដៅ -ប្រសិនបើជាអន្ទាក់ប្រើប្រាស់ទាប។ ខ.វិធីសាស្ត្រកាត់បន្ថយហានិភ័យ ដោយប្រើប្រាស់អន្ទាក់ស្នេហ៍ SCLP (Straights Chained Lepidopteran Pheromones)។	C	C ❋ មិនចាំបាច់សិក្សាអំពីហានិភ័យទេ ប្រសិនបើ៖ -មានក្លិនធួល -ការប៉ះពាល់ស្រដៀងគ្នាទៅនឹងកម្រិតនៃការប៉ះពាល់ធម្មជាតិ។ ❋❋ ការវាយតម្លៃហានិភ័យ ត្រូវបាន

			អនុវត្តប្រសិនបើផលិតផលចូលមាត់ ឬការប៉ះពាល់ទៅនឹងផលិតផលការពារដំណាំ។
៤	សេចក្តីអះអាងអំពីកម្រិតហានិភ័យទាប ឬគ្មានហានិភ័យបណ្តាលពីផលិតផល (Agents) ឬសមាសធាតុដែលប្រើប្រាស់	NA	R ភាពមិនសុទ្ធមិនមែនជាភ្នាក់ងារអន្ទាក់ស្នេហ៍ទេ កាលណាកំហាប់ច្រើនជាង១ក្រាមក្នុងមួយគីឡូក្រាមនៃសារធាតុសកម្ម គឺតម្រូវការសិក្សាពីលក្ខណៈគ្រោះថ្នាក់។
៥	សេចក្តីអះអាងអំពីកំហាប់ខ្យល់	NR	C
៦	សេចក្តីអះអាងអំពីសុវត្ថិភាពដល់អ្នកប្រើប្រាស់	NR	C -បានអនុវត្តប្រសិនបើផលិតផលចូលមាត់ ឬការប៉ះពាល់ទៅនឹងផលិតផល -ប្រសិនបើកំហាប់ខ្យល់ខ្ពស់ជាងកម្រិតធម្មជាតិ។
	(គ)- ជីវប្រសិទ្ធភាព		
៧	សេចក្តីអះអាងអំពីប្រសិទ្ធភាពនៃការទាក់ ឬបណ្តេញប្រឆាំងនឹងសរីរាង្គគោលដៅក្នុងទីវាល (ស្រែ ឬចម្ការបង្ហាញ)។ ប្រសិទ្ធភាពទាក់សត្វល្អិត អាចត្រូវបានពិសោធន៍តាមវិធីសាស្ត្រពីរយ៉ាង៖ -ប្រសិនបើផលិតផលនឹងត្រូវចុះបញ្ជី គឺជាម៉ូលេគុល ឬជាសមាសធាតុដែលប្រសិទ្ធភាពទាក់សត្វជៀបនឹងការទាក់ ឬប្រសិនបើមានពាក្យបណ្តឹងនៃផលិតផលនេះ មានយ៉ាងជាក់លាក់ការពាររុក្ខជាតិ បន្ទាប់មក	NR	R ឯកសារតម្រូវការផ្អែកលើការទាមទារនៃការការពារផលិតផលដំណាំ៖ -ប្រសិនបើការទាមទារមានទំហំធំបន្ទាប់ពីការអះអាង

	កស្តុតាងនៃឥទ្ធិពលលើការត្រួតពិនិត្យសត្វល្អិត ការខូចខាតដំណាំ ឬទិន្នផលដំណាំជាដើម -ផលិតផលធម្មតា ដែលមានប្រសិទ្ធភាពទាក់សត្វរួចហើយ ដែលត្រូវធៀបនឹងផលិតផលទាំងនោះ។		-បន្ទាប់ពីមានការអះអាងអំពីប្រសិទ្ធភាពការខូចខាតដំណាំ ឬទិន្នផលជាដើម។
	(ឃ)- ដំណើរការកែច្នៃ វេចខ្ចប់ និងការបិទស្លាកសញ្ញាព័ត៌មាន		
៨	ដំណើរការនៃការផលិត	NA	R
៩	ព័ត៌មានស្ដីពីការប្រើប្រាស់ និងការធ្វើសន្និធិ	C	R
១០	ការដាក់ស្លាកសញ្ញាព័ត៌មាន និងខិតប័ណ្ណផ្សព្វផ្សាយ	C	R

តម្រូវការថ្នាក់ទី ២

	(ង)- ទិន្នន័យកាកសំណល់ -ភាពពាក់ព័ន្ធនៅពេលមានកាកសំណល់នៃភ្នាក់ងារ-សកម្មនៃផ្នែកណាមួយអាចនឹងរំពឹងថានៅក្នុងចំណីអាហារ ឬគ្រឿងបរិភោគ -សារធាតុដែលត្រូវប្រើប្រាស់សម្រាប់ការផលិត មិនត្រូវបន្សល់កាកសំណល់ក្នុងចំណីអាហារ ឬគ្រឿង-បរិភោគ (គេត្រូវកត់ត្រាបញ្ហានេះនៅក្នុងឯកសារយោងពាក់ព័ន្ធ)។	C	C
	កំណត់សម្គាល់៖ -ទិន្នន័យកាកសំណល់មិនត្រូវបានទាមទារទេ ប្រសិនបើមិនទំនងមានកម្រិតកាកសំណល់ច្រើន ឬមិនទំនងលើសពីកម្រិតនៃការប៉ះពាល់ដល់ធម្មជាតិក្នុងអំឡុងពេលកើតឡើងសត្វល្អិត -គ្មានការវាយតម្លៃហានិភ័យបន្ថែមទៀតទេ បើសិនជាប៉ះពាល់ទៅនឹងក្លិនធូល (ដូចគ្នាទៅនឹងកម្រិតធម្មជាតិដែរ) -ការវាយតម្លៃហានិភ័យជាការចាំបាច់ ប្រសិនបើមានការសង្ស័យ ឬមានសំណើពីអ្នកប្រើប្រាស់។		
	(ច)- ទិន្នន័យស្ដីពីការប្រឈមនឹងសុខភាពមនុស្ស/ផលប៉ះពាល់បរិស្ថាន និងប្រសិទ្ធភាព	C	C
	កំណត់សម្គាល់៖ -ប្រសិនបើលទ្ធផលនៃតម្រូវការថ្នាក់ទី១ បានតម្រូវឲ្យធ្វើការវាយតម្លៃហានិភ័យក្នុងតម្រូវការថ្នាក់ទី២ទៀត		

	-តម្រូវការវាយតម្លៃផលប៉ះពាល់ ប្រសិនបើការប្រើប្រាស់លាយជាមួយគ្រាប់ពូជដំណាំ (ផលប៉ះពាល់អាចនៅក្នុងដី ទឹកក្រោមដី ផ្ទៃទឹក ឬក្នុងខ្យល់ អាចត្រូវបានពិចារណា)។		
	ឆ- តម្រូវការទិន្នន័យបន្ថែម	C	C

១០-សេចក្តីអះអាងរបស់អ្នកស្នើសុំ (Certification/ Clarification of Applicant)

ខ្ញុំសូមអះអាងថា រាល់ព័ត៌មាន និងឯកសារជូនភ្ជាប់ទាំងអស់សម្រាប់ស្នើសុំចុះបញ្ជី និងការកំណត់អត្តសញ្ញាណភ្នាក់ងារជីវសាស្ត្រ ខាងលើ គឺពិតជាត្រឹមត្រូវ ប្រាកដមែន។

ប្រសិនបើលទ្ធផលវាយតម្លៃតម្រូវការព័ត៌មានថ្នាក់ទី១ (Tier 1) នៅមិនទាន់គ្រប់គ្រាន់ សូមពិនិត្យព័ត៌មានបន្ថែមក្នុងតម្រូវការព័ត៌មានថ្នាក់ទី២ (Tier 2) ទៀត។

ដើម្បីជាសក្ខីភាពនាពេលនេះ ខ្ញុំសូមចុះហត្ថលេខា ឬផ្តិតមេដៃជាកស្តុតាង ដូចខាងក្រោម៖

រាជធានីភ្នំពេញ, ថ្ងៃទី (Day) .... ខែ (Month) .... ឆ្នាំ (Year) ២០ ...

ហត្ថលេខា និងត្រា (Signature/ Stamp of Firm)

១១-សម្រាប់នាយកដ្ឋាននីតិកម្មកសិកម្ម (Department of Agricultural Legislation use only)

-សំណុំឯកសារស្នើសុំលេខ (Document's application N^0) ....

-កាលបរិច្ឆេទទទួល (Received Date) ....

-វិក្កយបត្របង់ប្រាក់សេវាកម្មលេខ (Service Invoice N^o) ....

-វិក្កយបត្របង់ប្រាក់សេវាកម្មពិសោធន៍លេខ (Service Invoice for Analyze of BCA N^o) ....

-សំណាកសម្រាប់ធ្វើពិសោធន៍ (Sample for testing) ....

-កាលបរិច្ឆេទផុតសុពលភាព (Out of expiry's date) ....

-កំណត់សម្គាល់ (Note) ....

-ឈ្មោះមន្ត្រីទទួលឯកសារ និងសំណាក (Receiver name) ....

....។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ................ /................ កសក.ននក.បកជ   រាជធានីភ្នំពេញ, ថ្ងៃទី..........ខែ...............ឆ្នាំ២០....

វិញ្ញាបនបត្របញ្ជាក់បញ្ជិកាភ្នាក់ងារជីវសាស្ត្រ
BIOLOGICAL CONTROL AGENTS' REGISTRATION CERTIFICATE

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
បញ្ជាក់ថា

អ្នកស្នើសុំចុះបញ្ជី (Registrant) : ....
អាសយដ្ឋានបច្ចុប្បន្ន (Address) : ....
ត្រូវបានផ្ដល់បញ្ជិកាភ្នាក់ងារជីវសាស្ត្រ (Registered number) ៖ **លេខ** ....
ប្រភេទបញ្ជិកា (Type of registration)៖ ....
ប្រភេទភ្នាក់ងារការពាររុក្ខជាតិ (Type of Plant protection product)៖ ....
ឈ្មោះពាណិជ្ជកម្ម (Trade name) : ....
ឈ្មោះទូទៅ (Common name) : ....
ពាណិជ្ជសញ្ញា (Trade mark) : ....
ភាពពុល ឬភាពចម្លង (Toxicity/Infectivity) ៖ ....
ប្រភេទនៃទម្រង់ផ្សំ (Type of formulation)៖ ....
បរិមាណសារធាតុសកម្ម (Content of active ingredient)៖ ....
មុខសញ្ញាប្រើប្រាស់ (Use pattern) : ....
ក្រុមហ៊ុន និងប្រទេសផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មី (Manufactured/Formulated/Repackaged Company/Country)
:..។
សិទ្ធិលើទិន្នន័យ (Right on Data) ៖ មានសុពលភាពត្រឹមថ្ងៃទី .... ខែ .... ឆ្នាំ ....

វិញ្ញាបនបត្រនេះ ត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំចុះបញ្ជីដើម្បីប្រើប្រាស់ ដោយអនុលោមតាមប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ និងមានសុពលភាពត្រឹមថ្ងៃទី .... ខែ .... ឆ្នាំ .... លើកលែងតែមានការដកហូតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព (This certificate is issued in accordance with the provisions of the prakas on use of BCA's documents for business and unless sooner revoked by Ministry of Agriculture, Forestry & Fisheries, and will be expire on ....)។

តប.រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គលេខាធិការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ....កសក/ននក.នកជ

លិខិតអនុញ្ញាតនាំចូលនាំចេញភ្នាក់ងារជីវសាស្ត្រ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញប្រកាសលេខ ប្រក/កសក ចុះថ្ងៃទី ខែ .... ឆ្នាំ២០ ......
ស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ
- បានឃើញពាក្យស្នើសុំលេខ .... ចុះថ្ងៃទី.............ខែ..................ឆ្នាំ២០....

សម្រេច

អនុញ្ញាតឲ្យ ៖ លោក/លោកស្រី .... មុខងារ ....
អាសយដ្ឋានអចិន្ត្រៃយ៍ ៖ ....។
ធ្វើការ□នាំចូល□នាំចេញភ្នាក់ងារជីវសាស្ត្រ ក្នុងបរិមាណសរុប ៖ ....(□មានបញ្ជីភ្ជាប់)

យថាប្រភេទ លេខបញ្ជិកា បរិមាណ

....
....
....
....
....

ប្រភព និងទិសដៅ ៖ ប្រទេសប្រភពដើម □នាំចេញ □នាំចូល...
មាត់ច្រក ៖ ....។

លិខិតអនុញ្ញាតនេះ ត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់ ដោយអនុលោមតាមប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ ក្នុងសុពលភាពរយៈពេល០១ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ នឹងត្រូវផុតសុពលភាពនៅថ្ងៃទី ខែ .... ឆ្នាំ២០ ...... លើកលែងតែមានការដកហូតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ .... ឆ្នាំ២០ ......
តប.រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គលេខាធិការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ .... កសក/ននក.យកជ

វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិភ្ជាក់ងារជីវសាស្ត្រ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញប្រកាសលេខ **ប្រក/កសក** ចុះថ្ងៃទី ខែ ឆ្នាំ២០ .... ស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ
- បានឃើញពាក្យស្នើសុំលេខ.......................... ចុះថ្ងៃទី.........ខែ.................ឆ្នាំ២០

បញ្ជាក់ថា

ឈ្មោះ និងទីតាំងឃ្លាំងសន្និធិ ៖ ....
....។
មានសមត្ថភាពធ្វើសន្និធិប្រចាំឆ្នាំ.................................តោន **មានផ្ទៃសន្និធិ**........................ម៉ែត្រការ៉េ
ត្រូវបានចុះបញ្ជីជាឃ្លាំងសន្និធិភ្នាក់ងារជីវសាស្ត្រ របស់លោក/លោកស្រី...
មុខងារ...អាសយដ្ឋានអចិន្ត្រៃយ៍...
....
លេខបញ្ជិកាឃ្លាំង ៖ ....

វិញ្ញាបនបត្រនេះ ត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់ ដោយអនុលោមតាមប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ ក្នុងសុពលភាពរយៈពេល**៣**ឆ្នាំដោយគិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រនេះ នឹងត្រូវផុតសុពលភាពនៅចុះថ្ងៃទី ខែ ឆ្នាំ២០ លើកលែងតែមានការដកហូតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០

តប.រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គលេខាធិការ

អាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ៖ (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ៖ (៨៥៥) ២៣ ២១៧ ៣២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ....កសក/ននក.ផភជ

លិខិតអនុញ្ញាត
ផ្គត់ផ្គង់ចែកចាយភ្នាក់ងារជីវសាស្ត្រ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញប្រកាសលេខ **ប្រក/កសក** ចុះថ្ងៃទី ខែ ឆ្នាំ២០ ស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ
- បានឃើញពាក្យស្នើសុំលេខ .... ចុះថ្ងៃទី .... ខែ .... ឆ្នាំ២០ ......

សម្រេច

អនុញ្ញាតឲ្យ ៖ លោក/លោកស្រី...មុខងារ ....

ក្រុមហ៊ុន/សាខារបស់ក្រុមហ៊ុន ៖ ....

អាសយដ្ឋានអចិន្ត្រៃយ៍ ៖ ....។

ធ្វើប្រតិបត្តិការផ្គត់ផ្គង់ចែកចាយនូវប្រភេទ និងបរិមាណនៃភ្នាក់ងារជីវសាស្ត្រ ស្របតាមពាក្យស្នើសុំ ៖ ....។

លិខិតអនុញ្ញាតនេះ ត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់ ដោយអនុលោមតាមប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ ក្នុងសុពលភាពរយៈពេល៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ នឹងត្រូវផុតសុពលភាពនៅថ្ងៃទី .... ខែ .... ឆ្នាំ២០ .... លើកលែងតែមានការដកហូតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រាជធានីភ្នំពេញ, ថ្ងៃទី .... ខែ .... ឆ្នាំ២០ ......

តប.រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គលេខាធិការ

អាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ៖ (៨៥៥) ២៣ ២១៧ ៣២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ .... កសក/ននក.ប្រកជ

លិខិតអនុញ្ញាត
ប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីភ្នាក់ងារជីវសាស្ត្រ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញប្រកាសលេខ .... **ប្រក/កសក** ចុះថ្ងៃទី .... ខែ .... ឆ្នាំ២០ .... ស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ
- បានឃើញពាក្យស្នើសុំលេខ .... ចុះថ្ងៃទី .... ខែ .... ឆ្នាំ២០ ....

សម្រេច

អនុញ្ញាតឲ្យ ៖ លោក/លោកស្រី.......................................មុខងារ...

អាសយដ្ឋានអចិន្ត្រៃយ៍ ៖ ....

ធ្វើប្រតិបត្តិការ ៖ ....

សមត្ថភាពប្រចាំឆ្នាំ ៖ ....តោន/ឆ្នាំ

ឈ្មោះ និងទីតាំងគ្រឹះស្ថាន ៖ ....

....។

លិខិតអនុញ្ញាតនេះ ត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់ ដោយអនុលោមតាមប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ ក្នុងសុពលភាពរយៈពេល**៣**ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ នឹងត្រូវផុតសុពលភាពនៅថ្ងៃទី .... ខែ .... ឆ្នាំ២០ .... លើកលែងតែមានការដកហូតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រាជធានីភ្នំពេញ, ថ្ងៃទី............ ខែ .... ឆ្នាំ២០......

តប.រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គលេខាធិការ

អាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ៖ (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ៖ (៨៥៥) ២៣ ២១៧ ៣២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
....

រូបថត ៤x៦

លេខ .... មកសក/កនក.អកជ

លិខិតអនុញ្ញាត
អាជីវកម្មលក់ដុំលក់រាយភ្នាក់ងារជីវសាស្ត្រ

យោង៖ - ប្រកាសលេខ **ប្រក/កសក** ចុះថ្ងៃទី ខែ ឆ្នាំ២០
ស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ
- ពាក្យស្នើសុំរបស់ ចុះថ្ងៃទី ខែ ឆ្នាំ២០

អនុញ្ញាតឲ្យ៖ ឈ្មោះ ភេទ ឆ្នាំកំណើត សញ្ជាតិ
សាខារបស់ក្រុមហ៊ុន ៖
អាសយដ្ឋានអចិន្ត្រៃយ៍៖ ។

ធ្វើអាជីវកម្មលក់ដុំលក់រាយនូវប្រភេទ និងបរិមាណនៃភ្នាក់ងារជីវសាស្ត្រ ស្របតាមពាក្យស្នើសុំ ៖ ។

ឈ្មោះ និងទីតាំងគ្រឹះស្ថានលក់ដុំលក់រាយ ៖
។

លិខិតអនុញ្ញាតនេះ ត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់ ដោយអនុលោមតាមប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ ក្នុងសុពលភាពរយៈពេល**៣**ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ នឹងត្រូវផុតសុពលភាពនៅថ្ងៃទី ខែ ឆ្នាំ២០ លើកលែងតែមានការដកហូតដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

បានឃើញនិងឯកភាព ...., ថ្ងៃទី ខែ ឆ្នាំ២០

ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រធានការិយាល័យនីតិកម្មកសិកម្ម**

សាលាក្រុង/ស្រុក.............................. **ព្រះរាជាណាចក្រកម្ពុជា**

ការិយាល័យច្រកចេញចូលតែមួយ **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ .... /អកជ

រូបថត ៤x៦

លិខិតអនុញ្ញាត

អាជីវកម្មលក់ដុំលក់រាយភ្លាក់ងារជីវសាស្ត្រ

យោង ៖ - ប្រកាសលេខ **ប្រក/កសក** ចុះថ្ងៃទី ខែ ឆ្នាំ២០
ស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ

- ប្រកាសលេខ ៤២១ **ប្រក/កសក** ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ ស្តីពីការធ្វើប្រតិភូកម្មមុខងារនៃវិស័យកសិកម្ម ជូនការិយាល័យច្រកចេញចូលតែមួយនៅក្រុង- ស្រុកគោលដៅ

- ពាក្យស្នើសុំរបស់ ចុះថ្ងៃទី ខែ ឆ្នាំ២០

អនុញ្ញាតឲ្យ ៖ ឈ្មោះ ភេទ ឆ្នាំកំណើត សញ្ជាតិ

សាខារបស់ក្រុមហ៊ុន ៖

អាសយដ្ឋានអចិន្ត្រៃយ៍ ៖ ។

ធ្វើអាជីវកម្មលក់ដុំលក់រាយនូវប្រភេទ និងបរិមាណនៃភ្លាក់ងារជីវសាស្ត្រ ស្របតាមពាក្យស្នើសុំ ៖ ។

ឈ្មោះ និងទីតាំងគ្រឹះស្ថានលក់ដុំលក់រាយ ៖ ....។

លិខិតអនុញ្ញាតនេះ ត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់ ដោយអនុលោមតាមប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ ក្នុងសុពលភាពរយៈពេល**៣**ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ នឹងត្រូវផុតសុពលភាពនៅថ្ងៃទី ខែ ឆ្នាំ២០ លើកលែងតែមានការដកហូតដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

បានឃើញនិងឯកភាព ថ្ងៃទី ខែ ឆ្នាំ២០

អភិបាលនៃគណៈអភិបាលក្រុង/ស្រុក **ប្រធានការិយាល័យច្រកចេញចូលតែមួយ**

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្ដីការគណៈរដ្ឋមន្ត្រី